**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា**
**ការិយាល័យផ្នែករកប្រាក់ជំនួយ និងធ្វើតាមតម្រូវការ**
**440 NORTH BROAD STREET**
**PHILADELPHIA, PENNSYLVANIA 19130-4015**

**Cari Cantor**
**ប្រធាន**

ថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ២០១៨

ជូនចំពោះមាតាបិតា៖

ក្នុងនាមជាមាតាបិតារបស់សិស្សដែលរៀននៅសាលាដែលទទួលប្រាក់ជំនួយ Title I ពីរដ្ឋសហព័ន្ធ លោកអ្នកមានសិទ្ធិដឹងពីលក្ខណៈសម្បត្តិនៃជំនាញរបស់ គ្រូ និង គ្រូជំនួយ ដែលបង្រៀនកូនរបស់លោកអ្នក។

ច្បាប់រដ្ឋសហព័ន្ធតម្រូវឲ្យក្រសួងអប់រំដែលទទួលប្រាក់ជំនួយ Title I ទាំងអស់ អនុលោមតាម និងផ្តល់ជូននូវព័ត៌មានដែលលោកអ្នកបានស្នើសុំឲ្យទាន់ពេលវេលា។ សាលាទាំងអស់មានបញ្ជីឈ្មោះបុគ្គលិក និងលក្ខណៈសម្បត្តិនៃជំនាញរបស់ពួកគេ។

បើសិនជាលោកអ្នកចង់ដឹងព័ត៌មានអំពីលក្ខណៈសម្បត្តិនៃជំនាញ ដែលទាក់ទងនឹង គ្រូ ឬ គ្រូជំនួយ របស់កូនលោកអ្នក សូមទូរស័ព្ទទៅសាលា ធ្វើការណាត់ជួបដើម្បីនិយាយជាមួយនាយកសាលា ឬអ្នកតំណាងរបស់គាត់។

យើងខ្ញុំទន្ទឹងរង់ចាំឆ្នាំសិក្សាដែលមានការរីកចម្រើន ហើយយើងខ្ញុំមានជំនឿថា តាមរយៈនៃការសហការគ្នា យើងនឹងធ្វើឲ្យមានការផ្លាស់ប្តូរដល់ជីវិតរបស់កូនលោកអ្នក។

ដោយសេចក្តីស្មោះស្ម័គ្រ

Cari D. Cantor
ប្រធាន ការិយាល័យផ្នែកកម្មវិធីរបស់រដ្ឋសហព័ន្ធ